# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីការត្រាស់ដឹងច្បាប់ហេតុផលរបស់ព្រះពុទ្ធជាម្ចាស់

web site: hoksavann.org

ថ្ងៃទី៤ មីនា ២០០៥

ព្រះពុទ្ធជាម្ចាស់បានត្រាស់ដឹងច្បាប់ហេតុផល ដែលកើតឡើងក្នុងលោក គឺត្រាស់ដឹងពិតទៅតាមពិត បាលីថាយថាភូតញាណទស្សនៈ ប្រែថាប្រាជ្ញាឃើញទៅតាមសភាពពិតដែលកើតឡើង ។ ក្នុងពេលនេះ សូមលើកយកតែហេតុផលមួយ ដែលទាក់ទងនឹងរូបរាងកាយនិងចិត្តគំនិតរបស់មនុស្ស ក្នុងធម៌ដែលហៅថា «បដិច្ចសមុប្បាទធម៌» ។ ពាក្យថា បដិច្ចសមុប្បាទធម៌ប្រែថា ធម៌កើតឡើងព្រមព្រោះអាស្រ័យហេតុ ។ មានន័យដោយសង្ខេប គឺរបស់នេះមាន របស់នោះក៏មានដែរ «ឥទំហោតិ», របស់នេះកើតឡើង របស់នោះក៏កើតឡើងដែរ «ឥមស្សុប្បាទោ ឥទំឧប្បជ្ជតិ», របស់នេះរលត់ របស់នោះក៏រលត់ដែរ «ឥមស្ស និរោធោ ឥទំ និរុជ្ឈតិ» ។ គឺផលមួយកើតឡើង ព្រោះមានហេតុរបស់វា ហើយផលនោះធ្វើជាហេតុម្តងសំរាប់បង្កើតផលមួយជាបន្តទៅទៀត មានរហូតដល់១២ប្រការដូចជា វណ្ណមណ្ឌលមួយថ្លក់ជាប់បន្តគ្នា ហៅថា បដិច្ចសមុប្បាទធម៌ ។ ធម៌ទាំង១២ប្រការនោះគឺ អវិជ្ជា សង្ខារ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា តណ្ហា ឧបាទាន ភព ជាតិ ជរាមរណៈ ។ ធម៌១២ប្រការនេះហើយដែលហៅថា វដ្តសង្សារ ធ្វើឲ្យមនុស្សសត្វវិលកើតវិលស្លាប់ ។ មានវដ្តៈ៣គឺ អវិជ្ជា តណ្ហា ឧបាទាន ឈ្មោះថា កិលេសវដ្តៈ ។ កម្មភពនិងសង្ខារ ឈ្មោះថា កម្មវដ្តៈ ។ ឧបបត្តិភព វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ជាតិ ជារាមរណៈ ឈ្មោះថា វិបាកវដ្តៈ ។ អ្វីដែលហៅថា អវិជ្ជា ? គម្ពីរមជ្ឈិមនិកាយនិយាយថា ការមិនស្គាល់ទុក្ខ មិនស្គាល់កំណើតនៃទុក្ខ មិនស្គាល់ការរំលត់ទុក្ខ មិនស្គាល់ផ្លូវប្រតិបត្តិទៅកាន់ការរំលត់ទុក្ខ ម្នាលភិក្ខុទាំងឡាយ នេះហើយដែលតថាគតហៅថាអវិជ្ជា ។ ដូច្នេះ អវិជ្ជាពុំមែនទឹកដីភ្លើងខ្យល់ទេ, អវិជ្ជាគឺចិត្តដែលពុំដឹងឬពុំស្គាល់នូវសច្ចធម៌នេះឯង ។ កាលណាពុំដឹងនាំឲ្យមានសង្ខារ គឺចេតនាឬបំណងផ្លូវចិត្ត ឬចលនាផ្លូវគំនិតនៅក្នុងលោក ដែលបង្កើតជាវិបាកវិញ្ញាណចាប់បដិសន្ធិបន្តទៅទៀត, បន្ទាប់មកជាហេតុឲ្យមាននាមនិងរូបឬចិត្តនិងរូបបានដល់ខន្ធ៥ (រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ) ។ នាមនិងរូបជាហេតុនាំឲ្យមានអាយតនៈ៦គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្ត ។ អាយតនៈ៦នេះហើយដែលនាំឲ្យមានផស្សៈ គឺការប៉ះទង្គិចអាយតនៈខាងក្រៅ៦គឺ រូប សម្លេង ក្លិន រស សម្ផស្ស និងធម្មៈ ។ ធម្មៈបានដល់អ្វីទាំងអស់ដែលចិត្តនឹកគិត ឬទាញយកមកជាអារម្មណ៍ ដែលហៅថា ធម្មារម្មណ៍ ។ ផស្សៈនាំឲ្យមានវេទនា គឺការទទួលអារម្មណ៍ជាសុខជាទុក និងជាឧបេក្ខា ។ វេទនានាំឲ្យមានតណ្ហា គឺចំណង់ ។ តណ្ហានាំឲ្យមានឧបាទាន គឺការប្រកាន់ខ្ជាប់ ។ ឧបាទាននាំឲ្យមានភព គឺទីកើត ។ ភពនាំឲ្យមានជាតិគឺកំណើតណាមួយក្នុងភពនោះ ។ ជាតិនាំឲ្យមានជរានិងមរណៈ គឺចាស់និងស្លាប់ ។ ឯសេចក្តីសោកខ្សឹកខ្សួលការទោមនស្សតូចចិត្ត ការចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏កើតឡើងព្រោះមានជាតិជាបច្ច័យ។ ធម៌នេះព្រះសម្ពុទ្ធបានលើកយកមកពិចារណាភ្ជាប់ជាមួយរូបធម៌និងនាមធម៌ ដែលមានមានទំនាក់ទំនងរវាងហេតុនិងផលជាអនុលោមនិងបដិលោម គឺបណ្តោយនិងបញ្ច្រាស ទើបព្រះអង្គត្រាស់ដឹងនូវអរិយធម៌សច្ចៈ៤ ។ ដើម្បីងាយយល់អំពីសភាពនិងលក្ខណៈនៃរូបធម៌នៃរូបធម៌និងនាមធម៌នេះ គប្បីពិចារណានូវន័យភេទ៤ប្រការ ទើបអាចដឹងថារូបរាងកាយ ចិត្តគំនិតរបស់បុគ្គលមួយរូបៗ ពុំមែនជារបស់ខ្លួនពិតទេ គឺវាកើតឡើងដោយហេតុបច្ច័យ ហើយត្រូវរលត់ទៅវិញជាធម្មតាពុំស្តាប់បញ្ជាអ្នកណាឡើយ នេះជាច្បាប់ធម្មជាតិ ។ ន័យភេទ៤ប្រការនោះគឺ ១-ឯកត្តន័យ = រូបធម៌និងនាមធម៌ (ខ្លួនយើងនេះ) ជាធម្មជាតិតែមួយនៅជាមួយគ្នា; ២- នានត្តន័យ = រូបធម៌នឹងនាមធម៌នេះមានលក្ខណៈផ្សេងៗពីគ្នា គឺរូបមានលក្ខណៈទ្រុឌទ្រោមទៅវិនាសទៅ ឯនាមជាធម្មជាតិចេះរេទៅ ឯនាមជាធម្មជាតិចេះរេទៅ ចេះឱនទៅរកអារម្មណ៍; ៣- អព្យាបាន័យ = រូបធម៌និងនាមធម៌នេះ ពុំចេះខ្វល់ខ្វាយដល់គ្នានិងគ្នាឡើយ គឺរូបពុំដឹងនាមៗពុំដឹងរូប ថាឲ្យមកអាស្រ័យនឹងខ្លួនឡើយ; ៤- ឯវំធម្មតាន័យ = ទោះបីរូបនិងនាមពុំដឹងគ្នាក៏ដោយ បើរូបនាមនេះធ្វើបាបតែងបានផលបាប ធ្វើបុណ្យតែងបានផលបុណ្យគ្រប់កាលទាំងបី គឺអតីតជាតិ បច្ចុប្បន្នជាតិ និងអនាគតជាតិ ។ បាបបុណ្យនេះស្ថិតនៅក្នុងមនោ ប្រៀបដូចជារឿងរ៉ាវ ដែលគេចុចទុកក្នុងកុំព្យូទ័រ (computer) ទោះបីបុគ្គលចែកស្ថានទៅដល់បាបបុណ្យដែលគេបានធ្វើក្នុងជាតិដែលកន្លងហើយនិងបន្តឲ្យផលនៅក្នុងជាតិបន្តទៅទៀត ។ ដើម្បីបញ្ជាក់ថា តើត្រូវបន្តការទទួលផលនៃបាបបុណ្យនេះរបៀបណា គប្បីពិនិត្យមើលចម្លើយក្នុងមិលិន្ទបញ្ហាថា ភ្លើងដែលឆេះពីក្បាលព្រលប់ ដល់ពាក់កណ្តាលអាធ្រាត្រ រហូតដល់ភ្លឺ ពុំមែនជាភ្លើងដដែលទេ គឺជាភ្លើងថ្មីតែវាទាក់ទងពីភ្លើងចាស់ គឺភ្លើងដែលឆេះពីក្បាលព្រលប់ យ៉ាងណាមិញបាបនិងបុណ្យដែលបុគ្គលបានសាងក្នុងរូបនិងនាមដែលកន្លងហើយ វាត្រូវបន្តឲ្យផលក្នុងរូបនិងនាមមួយទៀត ។ នេះពោលអំពីបុគ្គលបុថុជ្ជនទូទៅដែលនៅមានអវិជ្ជា តណ្ហា ឧបាទាន កម្ម ជាហេតុជាបច្ច័យបន្តជាតិកំណើតតទៅទៀត វៀរលែងតែព្រះអរហន្តទាំងឡាយមានព្រះពុទ្ធជាដើម លោកកាត់ផ្តាច់នូវហេតុបច្ច័យនេះហើយ ទើបលោកពុំបន្តជាតិកំណើតដែលជាតួទុក្ខតទៅទៀតទេ លោកបរិនិព្វានជាទីបរមសុខ ។ ព្រះពុទ្ធដីកាពោលថា យំ អនិច្ចំ តំ ទុក្ខំ របស់ណាពុំទៀង របស់នោះជាទុក្ខ របស់ណាពុំទៀងជាទុក្ខ របស់នោះជាអនត្តា គ្មានខ្លឹមសារពុំសាប់បង្គាប់បញ្ជា ។ នេះជាន័យសេចក្តីតាមបរមត្ថអភិធម្ម ជាគម្ពីរដ៏មានជំរៅរបស់ព្រះពុទ្ធសាសនា ។

ជនជាតិខ្មែរធ្លាប់មានអារ្យធម៌ដ៏ខ្ពង់ខ្ពស់តាំងពីសម័យបូរាណ បានគោរពព្រះពុទ្ធសាសនា ទុកជាមាគ៌ាប្រចាំជីវិតរបស់ខ្លួន ដោយពិចារណាឃើញថា ព្រះពុទ្ធសាសនាមានពាក្យប្រៀនប្រដៅដ៏ត្រឹមត្រូវ ក្នុងការដឹកនាំខ្លួននិងសង្គមខ្មែរឲ្យបានសុខសាន្ត ។ ដូចបានពោលមកហើយ របស់អ្វីមួយបានកើតឡើង សុទ្ធតែកើតឡើងពីហេតុបច្ច័យ គ្មានអ្វីមួយកើតឡើងប្រាសចាកហេតុបច្ច័យឡើយ ។ ព្រះពុទ្ធសំដែងថា គ្រប់ធម្មជាតិទាំងអស់កើតឡើងដោយខ្លួនឯង តាមធម្មតារបស់លោកធាតុឬចក្រវាឡដូចព្រះអាទិត្យ ព្រះច័ន្ទ ផែនដី ភ្នំ ទន្លេ សមុទ្រជាដើម គ្មានអ្នកណាបង្កើតទេ ។ ឯរបស់មានវិញ្ញាណដូចមនុស្សសត្វអន្ទោលស្លាប់កើតតាមអំពើរបស់ខ្លួន ពុំមែនព្រះជាអ្នកចាត់ចែងទេ ។ មួយទៀត ព្រះពុំសំដែងត្រង់ណាដែលពុំអាចលើកយកភស្តុតាងមកបញ្ជាក់ប្រាប់គេបានឡើយ ដូចព្រះអង្គមិនសំដែងថា ក្នុងលោកនេះ តើមនុស្សណាឈ្មោះអ្វីកើតមុនគេ

។ ព្រះអង្គមានព្រះពុទ្ធដីកាដោយលើកយកឧទាហរណ៍មួយមកបញ្ជាក់
ថា បើគេសួរថា កូនមាន់កើតមកពីណា មុខជាឆ្លើយថាកើតមកពីពងមាន់
ចុះពងមាន់កើតមកពីណា មុខជាឆ្លើយថា កើតមកពីមេមាន់ ចុះមេមាន់
កើតមកពីណា មុខជាឆ្លើយដដែលៗ កើតពីពងមានកូនមាន់ ពុំអាចកំណា
ត់បានថា មាន់ណាកើតមុនគេដែលអាចយកភស្តុតាងមកបញ្ជាក់ប្រាប់គេ
បានឡើយ ។ ព្រះពុទ្ធបានបញ្ជាក់បន្ថែមទៀតថា ប្រៀបដូចកង់រទេះមួយ
ដែលមានវង់មូល ហើយគេបង្វិលឲ្យវិល គេពុំអាចកំណាត់ថាត្រង់ណាជា
ចំណុចដើមឡើយ ។ ព្រះពុទ្ធសាសនាក៏គ្មានពាក្យប្រៀនប្រដៅថា មនុ-
ស្សដើមដែលកើតមុនគេធ្វើបាបវាមានបាបដល់មនុស្សក្រោយទៀតដែ-
លមិនបានធ្វើបាបឡើយ ។ នេះជាទ្រឹស្តីអយុត្តិធម៌ណាស់ ព្រោះមនុស្ស
មុនមិនជឿព្រះ ព្រះអង្គឲ្យមានបាប ឲ្យបាបដល់អ្នកកើតក្រោយទៀត ។
តុលាការបច្ចុប្បន្ននេះ គេសំរេចឲ្យមានទោសចំពោះមនុស្សណាដែលប្រ
ព្រឹត្តខុស ។ ពុំមែនបានន័យថា ឪពុកម្តាយប្រព្រឹត្តខុស មានទោសតាម
ផ្លូវរដ្ឋ កូនដែលមិនបានប្រព្រឹត្តក៏ត្រូវមានទោសដូច្នេះឡើយ ។ ក្នុងពុទ្ធ
សាសនាក៏និយាយថា អ្នកដែលធ្វើបាបត្រូវទទួលផលបាបដោយខ្លួនឯង
។ ក្នុងព្រះពុទ្ធសាសនាក៏គ្មានទ្រឹស្តីថា មនុស្សណាជឿព្រះអង្គមានភក្តីភា
ពចំពោះព្រះអង្គ ព្រះអង្គសព្វព្រះទ័យឲ្យមនុស្សនោះកើតក្នុងស្ថានសួគ៌
ឯមនុស្សណាដែលមិនស្តាប់បង្គាប់ ព្រះអង្គដាក់បណ្តាសារមនុស្សនោះ
នឹងទទួលទុក្ខទោសរហូតឲ្យធ្លាក់នរកយ៉ាងនេះឡើយ ។ ព្រះពុទ្ធជាបុគ្គ-
លបរិសុទ្ធផុតចាកការបៀតបៀនហើយ ព្រះអង្គមិនឲ្យមនុស្សកើតស្ថាន
សួគ៌និងចុះនរកដោយសារមិនជឿព្រះអង្គឡើយ ប៉ុន្តែព្រះអង្គគ្រាន់តែ
បង្ហាញផ្លូវទៅកាន់ទីនោះប៉ុណ្ណោះ ទុកសិទ្ធិឲ្យមនុស្សសត្វសំរេចចិត្តធ្វើដំ
ណើរដោយខ្លួនឯង ។ សូម្បីព្រះអង្គសំដែងធម៌ ក៏គ្មានបង្ខំមនុស្សសត្វ
ឲ្យជឿធម៌ព្រះអង្គឡើយ ថែមទាំងព្រះអង្គរំលឹកថា មុននឹងជឿធម៌តថា-
គត ចូរអ្នកពិចារណាជាមុនសិន ។ បរិស័ទគ្រប់សាសនាទាំងអស់ ពុំមែន
ប្រតិបត្តិបានត្រឹមត្រូវតាមឱវាទសាសនារបស់ខ្លួនឡើយ តែងលាយឡំ
ដោយទំនៀមទម្លាប់ប្រពៃណីជាតិដែលមានជាច្រើនតំណមក ។ យ៉ាង
ណាមិញ ជនជាតិខ្មែរពេលមានទុក្ខ តែងបន់ស្រន់ឲ្យខ្លួនបាត់ទុក្ខជាដើម
ក៏ដូចជាព្រះសង្ឃសូត្រធម៌ជូនពរពុទ្ធបរិស័ទ ជាការលើកទឹកចិត្តឲ្យមាន
កម្លាំងផ្លូវចិត្តតាមរបបសុជីវធម៌ ជាមួយនោះមានប្រទានឱវាទឲ្យគេប្រព្រឹ
ត្តល្អ ដើម្បីឲ្យការជូនពរនោះមានប្រសិទ្ធិភាព ពុំមែនជាការខុសទេ ។ មា
នសាសនាមួយនិយាយថា ព្រះរបស់គេបង្កើតលោក ឯព្រះពុំមានសាច់
ឈាមរាងរៅអ្វីឡើយ គឺទ្រង់ជាព្រះវិញ្ញាណ ។ ព្រះពុទ្ធសាសនានិយាយ
ថា វិញ្ញាណកើតមានអាស្រ័យមានរូប គឺអាយតនៈ៦ ភ្នែក ត្រចៀក ច្រមុះ
អណ្តាត កាយ និងមនោ ប៉ះ (ផស្សៈ) និងអាយតនៈខាងក្រៅ រូប រាង ក្លិន
រស សម្ផស្ស និងធម្មា (ធម្មារណ៍) ទើបកើតចក្ខុវិញ្ញាណ សោតវិញ្ញាណ
ឃានវិញ្ញាណ ជីវ្ហាវិញ្ញាណ កាយវិញ្ញាណ និងមនោវិញ្ញាណ ។ ដូច្នេះព្រះ
ជារបស់អវិជ្ជមានទៅបង្កើតរបស់វិជ្ជមាន តើមានការពិតឬទេ ។ សាស-
នានោះនិយាយទៀតថា ព្រះអង្គបង្កើតអ្វីទាំងអស់ គ្មានវត្ថុនិងមនុស្ស
ណា ដែលព្រះមិនបានបង្កើតនោះទេ ព្រះធ្វើអន្តរាគមន៍បញ្ជាមនុស្ស
លោកតាំងពីនយោបាយទៅ រហូតទ្រង់អនុញ្ញាតឲ្យកើតខ្យល់ព្យុះភ្លើងភ្នំ
ផ្ទុះជាដើម ដោយមនុស្សមិនស្តាប់បង្គាប់ទ្រង់ៗត្រូវតែដាក់បណ្តាសារដូ
ច្នេះ ។ អស្ចារ្យណាស់ គ្រាន់តែគេមិនស្តាប់បង្គាប់ មិនធ្វើតាម ទៅធ្វើបា
បគេ នេះទុកជាការរំលោភសិទ្ធិនៃជំនឿរបស់គេ ដែលផ្ទុយពីរបបប្រជា
ធិបតេយ្យនិងយុត្តិធម៌ ។ ចំពោះព្រះពុទ្ធនិងព្រះពុទ្ធសាសនាវិញ ព្រះអង្គ
មិនធ្វើទោសបុគ្គលណាឡើយ ទោះបីគេមិនជឿធម៌ទេសនាព្រះអង្គក៏
ដោយ ដូចពួកនិគ្រន្ថមិនជឿហើយប្រឆាំងនឹងព្រះអង្គ ក៏មិនឃើញក្នុង
ពុទ្ធប្រវត្តិថា ព្រះអង្គតបទៅពួកនិគ្រន្ថទាំងនោះដោយហឹង្សាបែបណាមួ-
យឡើយ ។ សាសនានោះនិយាយបន្តទៀតថា គ្មានអ្វីមួយដែលព្រះបង្កើ
តឡើងដោយឥតប្រយោជន៍ឡើយ ។ សូមសួរតែវត្ថុមួយថា ចុះពោះវៀ
នដុះខ្នែង ព្រះបង្កើតឡើងដើម្បីអ្វី, មនុស្សគ្រប់រូបមានពោះវៀនដុះខ្នែង
បានសុខស្រួលនៅពេលដែលអាហារមិនទាន់ចូលទៅក្នុងពោះវៀននោះ
ទេ ពេលដែលអាហារចូលត្រូវឈឺចុកចាប់ បើមិនកាត់ចោលឲ្យបានឆាប់
ទេ នឹងទទួលគ្រោះថ្នាក់រហូតដល់ស្លាប់ ។ គេពោលថា ព្រះបង្កើតមនុ-
ស្សច្រើនផុនមានល្អមានអាក្រក់ ដើម្បីដឹងល្អត្រូវមានអាក្រក់ ។ ក្នុងពា-
ក្យនេះមានន័យថា គ្រាន់តែគេដឹងល្អ ទៅជាបង្កើតមនុស្សអាក្រក់ ឲ្យពិ-
ភពលោកមានទុក្ខដោយមនុស្សអាក្រក់ ដែលព្រះបង្កើតនេះបៀតបៀន។
អ្នកមានវិជ្ជាមានបញ្ញា គេយល់លក្ខណៈមនុស្សហើយ មិនបាច់បង្កើតម
នុស្សអាក្រក់ទើបដឹងមនុស្សល្អទេ ។ គេពោលថា មនុស្សពិការមានមនុ
ស្សខ្វាក់ជាដើមពុំមែនកើតឡើងដោយបាបខ្លួនឯង ពុំមែនឪពុកម្តាយ តែ
បណ្តាលឡើងពីព្រះជាម្ចាស់បណ្តាលឲ្យពិការមានខ្វាក់ជាដើមទើបព្រះ
អង្គព្យាបាលឲ្យជាដោយព្រះសំដែងក្នុងខ្លួនមនុស្សខ្វាក់នោះ ដើម្បីសំដែ
ងការលើកដម្កើងសិរីរុងរឿងនៃព្រះជាម្ចាស់ ។ ពាក្យនេះមានន័យថា
មនុស្សពិការមានខ្វាក់ជាដើមនេះ គឺព្រះធ្វើឲ្យខ្វាក់ ។ គ្រាន់តែចង់លើកដ
ម្កើងព្រះ បែរជាទៅធ្វើទុក្ខទោសដល់មនុស្ស ។ ធ្វើឲ្យគេឈឺហើយទៅ
ព្យាបាល ។ ឥឡូវនេះមនុស្សពិការខ្វាក់ខ្វិនគរថ្លង់ច្រើនណាស់ សូមព្រះ
យាងមកជួយព្យាបាលផង ដើម្បីជួយសំរាលគ្រូពេទ្យកុំឲ្យចំណាយថវិកា
ច្រើនពេក ។ គេពោលថា មនុស្សមានទុក្ខដោយសារមានបាប ខុសគ្នាពី
ព្រះពុទ្ធសាសនាដែលពោលថា មនុស្សមានទុក្ខដោយសារមានខន្ធ៥(
បញ្ចុបាទានខន្ធា ទុក្ខា) ។ តើពុទ្ធសាសនានិយាយការពិតឬទេ, មនុស្សចា
ស់ឈឺស្លាប់ ដោយមានការកើត គឺការកើតមានខន្ធ៥នេះឯង ។ ឯសោក
ទុក្ខ បរិទេវទុក្ខ ទោមនស្សទុក្ខ ឧបាយាសទុក្ខ ជាដើមកើតមានព្រោះមា
នជាតិជាបច្ច័យ ។ បើមនុស្សគ្មានបានទៅចុះ គ្រាន់តែបានសុខខ្លះក្នុងស្ថា
នមនុស្ស ប៉ុន្តែគេចពុំផុតពីជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខដែរ បើកើតស្ថាន
សួគ៌អស់បុណ្យត្រូវច្យុតវិលស្លាប់វិលកើតក្នុងវដ្តសង្សារដដែល សូមកុំ
បកស្រាយថា មនុស្សបើបានទៅកើតស្ថានសួគ៌ ទៅរស់នៅជាមួយព្រះ
មានជីវិតរស់រហូតដូច្នេះឡើយ ព្រោះស្ថានមនុស្សស្ថានសួគ៌ស្ថានព្រហ្ម
ជាភពបីស្ថិតនៅក្រោម អនិច្ចំ ទុក្ខំ អនត្តា ជាតួសង្ខតធម៌តែងវិលស្លាប់
វិលកើត មានតែព្រះនិព្វានទេ ដែលចេញផុតពីសង្ខតធាតុនេះ ជាអមតំ
និព្វានំ ប្រែថានិព្វានមិនស្លាប់ ។ គេនិយាយថា មានតែព្រះទេដែលអាច
សង្គ្រោះមនុស្សឲ្យផុតបាប ពុំមែនដោយការប្រព្រឹត្តទេ គឺដោយការស្រ
ឡាញ់មេត្តាពីព្រះ ដោយខ្លួនមានជំនឿទៅលើព្រះ ។ ចំពោះពុទ្ធសាសនា
វិញពោលថា សេចក្តីបរិសុទ្ធនិងមិនបរិសុទ្ធដោយខ្លួនឯង អ្នកដទៃពុំអាច
ញុំាងអ្នកដទៃឲ្យបរិសុទ្ធនិងសៅហ្មងបានឡើយ ។ ចិត្តជាធំជាប្រធានលើ
សកម្មភាពល្អអាក្រក់របស់មនុស្ស បើចង់ឲ្យចិត្តបរិសុទ្ធផុតបាប ត្រូវអប់រំ
ចិត្តនេះអំពើអាក្រក់គ្រប់យ៉ាងដោយខ្លួនឯង តាមពាក្យប្រៀនប្រដៅរប-
ស់ព្រះពុទ្ធ ។ ព្រះពុទ្ធសំដែងថា គ្មានឥទ្ធិពលខាងក្រៅណាមួយ ជួយឲ្យ
មនុស្សសត្វផុតទុក្ខឡើយ ។បើខ្លួនមិនប្រតិបត្តិខ្លួនឯងទេ ។ គេពោលថា
វិទ្យាសាស្ត្រគ្រាន់តែពន្យល់នូវអ្វីៗដែលព្រះបង្កើតឡើងប៉ុណ្ណោះ ។ អ្នក
ដែលពោលបែបនេះ តើបានឃើញព្រះលោកបង្កើតធម្មជាតិទាំងនោះ
ដោយផ្ទាល់ខ្លួន ឬសំអាងអ្វីដែលគេអាចថាជាការពិតបាន ព្រោះមិនថាតែ
ព្រះពុទ្ធសាសនាទេ ទោះបីក្រុមវិទ្យាសាស្ត្រក៏បានពោលស្របគ្នាថា ការ
កើតឡើងនៃធម្មជាតិនិងរចនាសម្ព័ន្ធរបស់ធម្មជាតិ វាប្រព្រឹត្តទៅនិងកើត
ឡើងដោយខ្លួនវា ។ គេពោលទៀតថា ពុទ្ធសាសនាថាពឹងខ្លួនឯង ចុះដូច

មនុស្សហែលក្នុងសមុទ្រ បើមិនពឹងកប៉ាល់ឬទូកទេ នឹងត្រូវស្លាប់ ។ នៅតែខ្លួនពឹងខ្លួនដដែល ព្រោះអ្នកដែលគេជួយនោះ ដោយសារមនុស្សល្អដែលគួរឲ្យគេជួយ បើជាមនុស្សចោរប្រព្រឹត្តអំពើឧក្រិដ្ឋ គេពុំបានសទ្ធាជួយទេ ហើយអ្នកនោះសុំឲ្យគេជួយផង ។ ដូចគ្រូពន្យល់សិស្ស បើសិស្សនោះមិនជួយខ្លួនឯងដោយខំប្រឹងស្តាប់ទេ ចំណេះវិជ្ជានោះពុំអាចចូលក្នុងខួរក្បាលសិស្សបានទេ ។ ក៏ដូចជាពុទ្ធបរិស័ទចង់សំរេចព្រះនិព្វានត្រូវប្រតិបត្តិខ្លួនឯង (អត្តទីបា) តាមព្រះធម៌គឺសីលសមាធិបញ្ញា (ធម្មទីបា) អ្វីដទៃទៀតពុំមែនជាទីពឹងរបស់អ្នករាល់គ្នាឡើយ (អនញ្ញសរណា) នេះជាពុទ្ធភាសិត ៕

❑